


## ដំណើរផ្លូវដ៏អស្ចារ្យរបស់យើង ៖ "ពីការរៀនខ្មាស ប្រែជាមានទំនុកចិត្តជាមួយនឹងទឹកមុខពោរពេញដោយស្នាមញញឹម"

កាលពីមុនខ្ញុំជាមនុស្សម្នាក់ ដែលពោរពេញដោយការខ្មាសអៀន និង មិនសូវមានទំនុកចិត្តលើខ្លួនឯង។ ខ្ញុំ មិនដែលមានក្តីស្រមៃ ឬ គិតពីជីវិតទៅថ្ងៃខាងមុខនោះទេ ព្រោះខ្ញុំត្រូវធ្វើការងារដើម្បីតែបំពេញក្រពះរបស់ខ្លួនប៉ុណ្ណោះ។ ជាឧទាហរណ៍ ពេលដែលខ្ញុំបើកម៉ូតូកង់បី (តុកតុក) ក្នុងគំនិតរបស់ខ្ញុំ គិតថាធ្វើម៉េចឱ្យទៅដល់គោលដៅឆាប់។ ដោយមិនដែលបានខ្វាយខ្វល់ពីអារម្មណ៍របស់អ្នកដទៃនោះទេ។ ខ្ញុំជាមនុស្សឧស្សាហ៍ម៉ូម៉ៅ និង ឆាប់ខឹងច្រើនណាស់។ ពេលខ្ញុំ នឹកគិតដល់រឿងពីមុន។ឡើងវិញ ខ្ញុំអាចមើលឃើញខ្លួនឯងថាមានភាពអត្មានិយម។ បើសិនជាពេលណាខ្ញុំនៅជាមួយក្រុមមនុស្សច្រើន ខ្ញុំដកខ្លួនចេញឆ្ងាយពីអ្នកដទៃដោយសារខ្ញុំមានអារម្មណ៍ខ្មាស់គេ និង ភ័យខ្លាច។

### "យើងទាំងអស់គ្នាជាសិស្សប្រៀបដូចជាគ្រាប់ស្រូវហើយសាកលវិទ្យាល័យរបស់យើងដូចជាថ្នាល ដែលបណ្តុះនូវធនធានមនុស្សយ៉ាងច្រើន" (សែន, ២០១៩)

ខ្ញុំមានឱកាសបានចូលរៀន វគ្គសិក្សាជំនាញវិជ្ជាជីវៈប្រឹក្សាផ្លូវចិត្ត នៅឆ្នាំ២០១៧ ហើយនៅក្នុងថ្នាក់រៀន ដែលមានបរិយាកាសទំនាក់ទំនងល្អជាមួយគ្នា វាពិតជាការលើកទឹកចិត្តខ្ញុំមែនទែនក្នុងការបន្តការសិក្សាបន្តទៀត។ រឿងទាំងអស់ ដែលខ្ញុំបានឆ្លងកាត់នេះ វាជាចំណែកមួយ ធ្វើឱ្យខ្ញុំមានទំនុកចិត្តលើខ្លួនឯង។ ខ្ញុំមិនមានអារម្មណ៍តិតភ័យ និង ខ្លាចដូចមុនទៀតនោះទេ។ ខ្ញុំឱ្យតម្លៃលើខ្លួនឯង និង សង្ឃឹមថានឹងមិនបង្កគ្រោះថ្នាក់ដល់អ្នកដទៃផងដែរ។ ខ្ញុំសង្ឃឹមថា ខ្ញុំនឹងក្លាយជាពលរដ្ឋល្អម្នាក់នៅក្នុងសង្គម។

ការសិក្សាជំនាញវិជ្ជាជីវៈជាអ្នកប្រឹក្សាផ្លូវចិត្ត បានធ្វើឱ្យខ្ញុំចង់ជួយប្រជាជន និង ប្រទេសជាទីស្រលាញ់របស់ខ្ញុំកាន់តែខ្លាំង។ អ្វីដែលខ្ញុំចង់ឃើញនោះ គឺប្រជាជនខ្មែរទាំងអស់គ្នាអាចទទួលបានការពីគ្រោះបញ្ហាផ្លូវចិត្តដែលមានជំនាញវិជ្ជាជីវៈ។ ជាសិស្សដំបូងក្នុងជំនាញវិជ្ជាជីវៈប្រឹក្សាផ្លូវចិត្ត ខ្ញុំសង្ឃឹមថាខ្ញុំអាចរួមចំណែកក្នុងការព្យាបាលរបួសផ្លូវចិត្តដល់ប្រជាជន ដែលទទួលរងការឈឺចាប់ផ្លូវចិត្ត។

កត្តាដែលលើកទឹកចិត្តជីវិតខ្ញុំនាពេលបច្ចុប្បន្ននេះ គឺមិត្តរួមថ្នាក់ អ្នកព្យាបាលផ្លូវចិត្ត អ្នកអតិបាល និង ជាពិសេសប្រពន្ធរបស់ខ្ញុំ គាត់យល់ពីខ្ញុំកាន់តែច្រើន និង ឱ្យតម្លៃក្នុងការសិក្សារបស់ខ្ញុំ។ គាត់បាននិយាយថា វាមិនមែនជាការងាយស្រួលនោះទេ ក្នុងការរៀនសូត្រ តែគាត់នូវតែលើកទឹកចិត្តខ្ញុំ ឱ្យបន្តការសិក្សា។ ខ្ញុំបានចែករំលែកនូវអ្វីដែលខ្ញុំបានរៀនជាមួយនឹងភរិយារបស់ខ្ញុំ ហើយវាជួយឱ្យគាត់យល់បានកាន់តែច្រើន ពីអ្វីជាសុភាពផ្លូវចិត្ត។ យើងយល់ពីគ្នាកាន់តែច្រើន ហើយយើងអាចរួមគ្នាដោះស្រាយបញ្ហាផ្សេង។ បានកាន់តែងាយស្រួលជាងមុន។ ថ្មី។នេះខ្ញុំបានចូលរួមជួយគាំទ្រនិស្សិតឆ្នាំសិក្សាថ្មីរបស់សាកលវិទ្យាល័យពុទ្ធសាស្ត្រ។ ពីដំបូងខ្ញុំមានអារម្មណ៍ភ័យខ្លាច ហើយពិបាកក្នុងការប្រមូលអារម្មណ៍ជាខ្លាំង។ ខ្ញុំមិនមានអារម្មណ៍សុខស្រួលនោះទេ ពេលសម្លឹងមើលសិស្សានុសិស្សទាំងអស់នោះ ប៉ុន្តែជាចុងក្រោយខ្ញុំអាចធ្វើវាបាន។ ខ្ញុំបានប្រាប់ខ្លួនឯងថាត្រូវតែ "ចេញពីកន្លែងធ្វើឱ្យខ្លួនមានភាពងាយស្រួល"។ បន្ទាប់ពីលោកគ្រូ និង ខ្ញុំបានបញ្ចប់សកម្មភាពទាំងអស់ ខ្ញុំមានមោទនភាពលើខ្លួនឯងមែនទែន ព្រោះខ្ញុំបានឈរនៅចំពោះមុខសិស្សជាច្រើន (ច្រើនជាង១០០នាក់) ដែលពីមុនខ្ញុំមិនធ្លាប់បានធ្វើវាពីមុនមកទេ។ ខ្ញុំក៏បានធ្វើការចែករំលែកនូវបទពិសោធន៍ និង ចំណេះដឹងរបស់ខ្លួនដល់សិស្ស។ទាំងអស់នោះ។

ពីរបីសប្តាហ៍បន្ទាប់ពីសិក្ខាសាលានេះ ខ្ញុំភ្ញាក់ផ្អើលមែនទែន ដែលមណ្ឌលប្រឹក្សាសុខភាពផ្លូវចិត្តប្រកបដោយវិជ្ជាជីវៈ និង សាកលវិទ្យាធិការ បានប្រគល់វិញ្ញាបនបត្រអរគុណមកដល់ខ្ញុំ។ ខ្ញុំអាចដឹងខ្លួនឯងថាបេះដូងរបស់ខ្ញុំ លោតញាប់ខ្លាំងណាស់ពេលនោះ។ ខ្ញុំមានអារម្មណ៍សប្បាយចិត្តយ៉ាងខ្លាំង ហើយវាជាការលើកទឹកចិត្តខ្ញុំកាន់តែខ្លាំងឡើងថែមទៀត។ មិត្តភក្តិរត់កងបីរបស់ខ្ញុំជាច្រើន សួរថាហេតុអ្វីខ្ញុំមិនរើសយក រៀនមុខវិជ្ជានេះ មិនទៅរៀនភាសាបរទេសវិញវាល្អជាង។ ខ្ញុំចង់ធ្វើការផ្លាស់ប្តូរជីវិតរបស់ខ្ញុំ ហើយធ្វើការអភិវឌ្ឍជំនាញរបស់ខ្ញុំបន្ថែមទៀត។





ខ្ញុំឥឡូវមានសេចក្តីសុខ និង ទទួលយកនូវសំណួររបស់អ្នកផ្សេងដែលបានសួរថា ខ្ញុំជាអ្នកបើកម៉ូតូកង់បីម្នាក់ "តុកតុក" ហេតុអ្វីចង់រៀនជំនាញនេះ ពួកគេមានសិទ្ធឆ្ងល់ហើយចង់ដឹង តែអ្វីដែលសំខាន់សម្រាប់ខ្ញុំនោះ គឺខ្ញុំធ្វើការសម្រេចបាននូវគោលបំណងរបស់ខ្ញុំ។ មិត្តភក្តិអ្នករត់ម៉ូតូកង់បី មានការភ្ញាក់ផ្អើល និង ជួយត្រេកអរពីអ្វីដែលខ្ញុំទទួលបានផងដែរ។ ពួកគាត់ចង់ឱ្យខ្ញុំបញ្ចប់ការសិក្សារបស់ខ្ញុំដោយជោគជ័យ ហើយប្រាប់ខ្ញុំថាជីវិតរបស់ខ្ញុំនឹងមានការផ្លាស់ប្តូរ។ ឥឡូវនេះខ្ញុំមានទំនុកចិត្តលើខ្លួនឯង និង ទទួលយកនូវអ្វីដែលជាខ្ញុំ។

ខ្ញុំ និង មិត្តរួមថ្នាក់ផ្សេង។ទៀត មានការងារជាច្រើនត្រូវបំពេញ មុនពេលបញ្ចប់ការសិក្សាមកដល់ក្នុងខែកក្កដាខាងមុខនេះ។ ប្រពន្ធ និង កូនរបស់ខ្ញុំនឹងមកចូលរួមថ្ងៃបញ្ចប់ការសិក្សារបស់ខ្ញុំ។

### "ឆ្លងកាត់ព្យុះភ្លៀងនិងការលំបាកទាំងឡាយវាប្រៀបដូចជាការឡើងភ្នំចុះភ្នំអញ្ចឹងដែរប៉ុន្តែបើសិនជាយើង "មានសង្ឃឹម" និង "ខិតខំប្រឹងប្រែង" យើងនឹងអាចជំនះវាបាន"

អ្វីដែលខ្ញុំចង់និយាយ គឺថា "ខ្ញុំអាចធ្វើវាបាន"។ ខ្ញុំពិតជារំភើប និង រីករាយមែនទែននូវថ្ងៃបញ្ចប់ការសិក្សា ដែលនឹងមកដល់ក្នុងពេលឆាប់។ខាងមុខនេះ។

"សូមអរគុណជាខ្លាំង ចំពោះអ្នកដែលបានឧបត្ថម្ភដល់ខ្ញុំក្នុងការសិក្សា គាត់បានផ្តល់ឱកាសដ៏អស្ចារ្យមួយដល់ខ្ញុំ។ ខ្ញុំក៏អរគុណខ្លួនឯងផងដែរ ដែលចាប់យកឱកាសមួយនេះ។ ខ្ញុំនឹងប្រឹងឱ្យអស់ពីសមត្ថភាពក្នុងការអភិវឌ្ឍ និង បង្កើនសមត្ថភាព "មួយចំហានម្តង។" ក្នុងការជួយប្រជាជនរបស់ខ្ញុំ"